# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

## សារជូនពរ

### សូមគោរពជូន

### សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា
### ក្នុងឱកាសអបអរសាទរខួបលើកទី១១៤ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៥

***សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

ក្នុងឱកាសអបអរសាទរខួបលើកទី១១៤ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៥ ក្រោមប្រធានបទ "សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រីនិងក្មេងស្រីគ្រប់រូប" តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សូមទទួលបាននូវសុខភាពល្អបរិបូរ ជន្មាយុ យឺនយូរ ដើម្បីដឹកនាំកាកបាទក្រហមកម្ពុជា ឱ្យទទួលបាននូវជោគជ័យថ្មីៗបន្តទៀត។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពកោតសរសើរយ៉ាងក្រៃលែងចំពោះសកម្មភាពដ៏ឧត្តុង្គឧត្តម របស់ **សម្តេច** កន្លងមក ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ប្រកបដោយឆន្ទៈដ៏ មោះមុតពុំខ្លាចនឿយហត់ យកចិត្តទុកដាក់ដល់សុខទុក្ខរបស់ប្រជាពលរដ្ឋ តាមរយៈសកម្មភាពមនុស្សធម៌ ផ្តល់នូវកិច្ចគាំពារសង្គម ការលើកកម្ពស់ស្ត្រី ទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទ ដោះស្រាយរាល់ទុក្ខលំបាករបស់ ប្រជាពលរដ្ឋដែលទទួលរងគ្រោះដោយសារគ្រោះមហន្តរាយផ្សេងៗ ពិសេសជនងាយរងគ្រោះដូចជាស្ត្រី និងកុមារ។ តាមរយៈសកម្មភាពដ៏ឧត្តុង្គឧត្តមនេះ បានឆ្លុះបញ្ចាំងពីតួនាទីដ៏សំខាន់ និងការចូលរួមយ៉ាងសកម្មរបស់ស្ត្រីនៅ ក្នុងសង្គម ក៏ដូចជាការចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទ និងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមតាមជួយ ថែរក្សាការពារប្រោះព្រំ ជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និង**សម្តេចតេជោ**ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រីជាទីស្រលាញ់ ជួបតែសុភមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការនិងប្រកបដោយពុទ្ធពរទាំងបួន ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** ទទួលនូវ ការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃសុក្រ ២ កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**